# ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......១០៣៣...អពដ

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០

## សេចក្តីជូនដំណឹង
*ស្តីពី*
## ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១០

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មេត្តាជ្រាបថា ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១០ ត្រូវអនុវត្តចាប់ពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ រហូតដល់ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០ ។ សម្រាប់ឆ្នាំ២០១០នេះ អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានខិតខំថែមទៀតក្នុងការផលិតលតាបត្រពន្ធ លើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដើម្បីត្រួតពិនិត្យលក្ខណៈពិតប្រាកដ និងក្លែងក្លាយរបស់លតាបត្រនេះ ។

ដើម្បីអនុវត្តការប្រមូល និងបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១០នេះឱ្យមានប្រសិទ្ធភាពត្រឹមត្រូវតាមច្បាប់ និងមានតម្លាភាពអគ្គនាយកដ្ឋានពន្ធដារសូមធ្វើការកំណត់បញ្ជាក់ចំណុចមួយចំនួនបន្ថែមទៀត ដល់ម្ចាស់យានយន្តទាំងអស់ឱ្យបានជ្រាបដូចខាងក្រោម:

១- ត្រូវបង់ពន្ធនៅចំទីតាំងប្រមូលពន្ធ ដែលមានភ្នាក់ងារពន្ធដារប្រចាំនៅទីនោះ ។

២- ចំពោះរថយន្តត្រូវផ្តល់ឯកសារបញ្ជាក់ពីការបង់ពន្ធឆ្នាំ២០០៩ ដល់ភ្នាក់ងារពន្ធដារដើម្បីផ្ទៀងផ្ទាត់ជាមួយព័ត៌មានឆ្នាំចាស់ និងបំពេញលិខិតប្រកាសតាមគំរូសម្រាប់បង់ពន្ធឆ្នាំ២០១០ ។ ចំពោះទោចក្រយានយន្ត ត្រូវពិនិត្យ កម្លាំង (ទំហំពិស្តុង) ឱ្យបានត្រឹមត្រូវដើម្បីបង់ពន្ធតាមលក្ខណៈបច្ចេកទេសនៃយានយន្តនោះ ។

៣- មុនបង់ពន្ធត្រូវពិនិត្យលើតារាងពន្ធដែលមានបិទនៅទីនោះ រួចហើយបង់ប្រាក់ពន្ធឱ្យគ្រប់តាមចំនួនទឹកប្រាក់ពន្ធកំណត់ក្នុងតារាងពន្ធ។ ក្នុងករណីភ្នាក់ងារពន្ធដារទារប្រាក់លើសពីចំនួនដែលបានកំណត់សូមរាយការណ៍អំពីឈ្មោះនិងអត្តលេខរបស់ភ្នាក់ងារពន្ធដារនោះមកកាន់អគ្គនាយកដ្ឋានពន្ធដារ ។

៤- ត្រូវបង់ប្រាក់ពន្ធដល់ដៃភ្នាក់ងារពន្ធដារនិងទទួលយកបង្កាន់ដៃបង់ពន្ធប័ណ្ណសម្រាប់បិទភ្ជាប់យានយន្តសំរាប់បញ្ជាក់ការបង់ពន្ធលើយានយន្ត។

៥- សូមកុំទិញប័ណ្ណបង់ពន្ធបន្តពីបុគ្គលដែលពុំមែនជាភ្នាក់ងារពន្ធដារមានសមត្ថកិច្ច ឬទិញប័ណ្ណបង់ពន្ធនៅទីកន្លែងខុសពីទីតាំង ប្រមូលពន្ធរបស់អង្គភាពពន្ធដារ ។

៦- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចាត់វិធានការតាមច្បាប់រួមជាមួយ ក្រសួងមានសមត្ថកិច្ច ដើម្បីចាប់ឃាត់ទុកជន ទាំងឡាយណាដែលបានលួចបន្លំបោះពុម្ពធ្វើអាជីវកម្មលក់ដូរ និងប្រើប្រាស់ប័ណ្ណក្លែងក្លាយទាំងនេះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រីដែលជាម្ចាស់យានយន្តទាំងអស់ មេត្តាជ្រាប និងបំពេញកាតព្វកិច្ចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសំរាប់ឆ្នាំ២០១០នេះ ដោយស្មារតីសហការ និងម្ចាស់ការ ។

អគ្គនាយកដ្ឋានពន្ធដារ

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PHNOM PENH
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨ / ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
Phone: (855) 23 886 708 / Fax: (855) 23 886 700